# ថ្ងៃបញ្ចប់នៃការធ្វើសក្ខីកម្មរបស់លោក វ៉ាន់ថាន់ ពៅដារ៉ា និងការចូលមកធ្វើសក្ខីកម្មបន្តរបស់សាក្សី ប្រាក់ យុត

*ដោយ វ៉េនឌុល ឌីហ្សាល់កូ*

*ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២*

*ប្រែសម្រួលដោយ ដា ដល្លា*

នៅថ្ងៃពុធ ទី២៥ ខែមករា ឆ្នាំ២០១២នេះ អង្គជំនុំជម្រះឈានដល់ថ្ងៃទីបីនៃការធ្វើសក្ខីកម្មរបស់លោក វ៉ាន់ថាន់ ពៅដារ៉ា មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មុននឹងលោក ដារ៉ា ឡើងនិយាយ ក្រុមការពារក្តីទាំងបីក្នុងករណី០០២ ជជែកពីរឿងអព្យាក្រិតភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានគោលបំណងស្រាវជ្រាវទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។

អំឡុងពេលនៃការសួរសំណួរកាលពីម្សិលមិញ ក្រុមការពារក្តីរបស់ នួន ជា និង អៀង សារី បានសួរទៅលោក ដារ៉ា ទាក់ទងទៅនឹងគោលបំណងនិងគោលនយោបាយ ព្រមទាំងដំណើរការចងក្រងឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ពេលខ្លះសំណួរហាក់បីដូចជាមានភាពចម្រូងចម្រាស់យ៉ាងខ្លាំង ដោយមេធាវីការពារក្តីបានតវ៉ាថា លោក ដារ៉ា មិនបានឆ្លើយឲ្យចំសំណួរទេ ហើយតវ៉ាអំពីអព្យាក្រឹត្យភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

## មេធាវីការពារក្តី អៀង សារី បន្តសួរសំណួរទៅលោក វ៉ាន់ថាន់ ពៅដារ៉ា

ថ្ងៃនេះ ក្រុមការពារក្តីរបស់ អៀង សារី ចាប់សួរសំណួរបន្ត ដោយលើកពីបញ្ហាមួយចំនួនថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានរៀបចំឯកសារដាក់លាក់ណាមួយ ដើម្បី«សំដៅ»ទៅជនជាប់ចោទក្នុងករណី០០២ដែរឬទេ? លោក ដារ៉ា បានបញ្ជាក់ថា មិនមានសំណុំឯកសារណាមួយសំដៅឲ្យចំជនជាប់ចោទនីមួយៗក្នុងករណី០០២ទេ ។ មេធាវី ខាណាវ៉ាស ក៏បានបង្ហាញឯកសារមួយដែលបានផ្តល់ជូនមកអង្គជំនុំជម្រះដោយលោក ដារ៉ា ខ្លួនឯងផ្ទាល់ ដែលមានសំណុំឯកសារទាក់ទងនឹងជនជាប់ចោទ អៀង សារី ។

ក្រោយពីមានបញ្ហាក្នុងការបកប្រែរវាងពាក្យ «សំណុំឯកសារ» និង«ប្រអប់ឯកសារ» លោក ដារ៉ា បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមាន«ប្រអប់ឯកសារ»ចំពោះជនចាប់ចោទនីមួយៗ ហើយប្រអប់ឯកសារទាំងនេះ ត្រូវបានបង្កើតឡើងដើម្បីជួយសម្រួលដល់អ្នកស្រាវជ្រាវដែលមកមជ្ឈ

មណ្ឌលឯកសារកម្ពុជាដើម្បីរកព័ត៌មានផ្សេងៗ ។ ក្រោយពីត្រូវបានចោទប្រកាន់ថា “មិនសូវមានភាពប្រាកដ” នូវអ្វីដែលបាននិយាយកន្លងមក លោក ដារ៉ា បានផ្តល់សក្ខីកម្មថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានរៀបចំឯកសារដោយរៀបរាប់ពីជនជាប់ចោទទេ ។

ក្រោយមក មេធាវី ខាណាវ៉ាស បានបង្ហាញសារអេឡេចត្រូនិចមួយដែលផ្ញើដោយអ្នកនិពន្ធ ភីធើ ម៉ាគៀ ទៅកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឆាំង យុ ដែលមានប្រធានបទថា“សំណុំរឿង អៀង ធីរិទ្ធ” ។ ពេលនោះ មេធាវី ខាណាវ៉ាស បានបង្ហាញសាអេឡិចត្រូនិចមួយទៀតដែលផ្ញើដោយ លោក ឆាំង យុ ទៅអ្នកប្រាជ្ញ ប៊ែន ឃៀនិន និងចម្លងជូន ហេឡេន ចាវីស ដែលមានចំណារសរសេរដោយដៃដែលបញ្ជាក់ថា “ដារ៉ា នេះជាសំណុំរឿង NC” ។ លោក ដារ៉ា ទទួលស្គាល់ពីខ្លឹមសារនៃចំណារនេះ ហើយពេលនោះ ព្រះរាជអាជ្ញាជំទាស់ទៅនឹងសំណុំឯកសារដែលជាឯកសារសារអេឡិចត្រូនិចនេះ ។

មេធាវី ខាណាវ៉ាស បានបញ្ជាក់ថា ឯកសារនោះមិនបានបញ្ចូលនៅក្នុងសំណុំឯកសារទេ ហើយបានប្រគល់ជូនឯកសារជាក្រដាសទៅព្រះរាជអាជ្ញា ។ ក្រោយមក មេធាវី ខាណាវ៉ាស បានស្នើទៅលោក ដារ៉ា ឲ្យអានចំណារដែលចារនៅលើឯកសារនោះ ។ ចំណុចនេះធ្វើឲ្យលោក ដារ៉ា មានការធុញថប់ព្រោះតែមេធាវីឲ្យលោកអានម្តងហើយម្តងទៀត ហើយមេធាវីក៏មិនសូវពេញចិត្តនូវការដែលលោក ដារ៉ា មិនសូវសហការក្នុងការឆ្លើយសំណួរនេះដែរ ។

ក្រោយមក ចៅក្រម ស៊ីលវៀ ខាត់វ្រាយត៍ ចូលមកអន្តរាគមន៍ដោយបញ្ជាក់ថា ធម្មតាឯកសារនៅក្នុងសំណុំរឿងមិនត្រូវយកមកប្រើប្រាស់ដើម្បីសួរសំណួរនៅក្នុងច្បាប់ស៊ីវិលទេ លោកស្រីចៅក្រមបានស្នើទៅមេធាវី ខាណាវ៉ាស ឲ្យពន្យល់បន្ថែមទៀតអំពីឯកសារជាសារអេឡិចត្រូនិចនោះ ។

មេធាវី ខាណាវ៉ាស បានពន្យល់ថា ឯកសារជាសារអេឡិចត្រូនិចនោះទទួលបានតែក្រុមការពារក្តីរបស់ អៀង សារី ប៉ុណ្ណោះ ហើយមិនទាន់ដាក់បញ្ចូលនៅក្នុងសំណុំឯកសារនៅឡើយទេ ព្រោះទើបតែទទួលបានរសៀលម្សិលមិញប៉ុណ្ណោះ ។ មេធាវី មិនអាចបង្ហាញអត្តសញ្ញាណអ្នកដែលបានផ្តល់ឯកសារនោះទេ ព្រោះលោកត្រូវលាក់ការសម្ងាត់ដល់អ្នកដែលផ្តល់ឯកសារនោះ ។ ក្រោយពីពិភាក្សាគ្នារវាងអង្គជំនុំជម្រះ និងភាគីការពារក្តីរួចមក មេធាវី ខាណាវ៉ាស បានបញ្ជាក់ថា ឯកសារនោះត្រូវផ្តល់ក្រេឌីតទៅលោក ដារ៉ា ជាសាក្សី ព្រោះលោកបានធ្វើសក្ខីកម្មកាលពីម្សិលមិញថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានបង្កើតសំណុំឯកសារណាមួយសម្រាប់ជនជាប់ចោទណាមួយទេ ។

ប្រធានចៅក្រមអង្គជំនុំជម្រះ និល ណុន បានជំទាស់ដោយមិនអនុញ្ញាតិឲ្យមានការប្រើប្រាស់ឯកសារជាសារអេឡិចត្រូនិចទេ ហើយចៅក្រមបានបញ្ជាក់ថា ភ័ស្តុតាងត្រូវតែដាក់បញ្ចូលទៅក្នុងសំណុំ

ឯកសារមុននឹងយកមកនិយាយ ។ ចៅក្រម ខាណាវ៉ាស ទទួលយកនូវការណែនាំនេះ ហើយបានបញ្ជាក់ថា ឯកសារគួរតែផ្តល់ជូនដើម្បីដាក់បញ្ចូលនៅក្នុងសំណុំរឿង ។ ក្រោយមក មេធាវីរូបនេះបញ្ជាក់ថា មេធាវីការពារក្តីរបស់ អៀង សារី ប្រហែលជាប្រើឯកសារនេះនៅថ្ងៃអនាគតពេលដែលនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឆាំង យុ ឡើងមកធ្វើសក្ខីកម្ម ហើយអង្គជំនុំជម្រះបានបញ្ជាក់ថានឹងកោះអញ្ជើញលោក ឆាំង យុ ក្នុងនាមជាសាក្សី ។

បន្ទាប់មកមេធាវី ខាណាវ៉ាស បានងាកមកសួរថាតើមានការ«វិភាគ»ដើម្បីឲ្យដឹងអំពីយថាភាពនិងភាពអាចទុកចិត្តបានដែរឬទេចំពោះឯកសារដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សំណួរនេះបង្កឲ្យមានការជំទាស់ពីព្រះរាជអាជ្ញាដែលអះអាងថា មេធាវី ខាណាវ៉ាស មិនគួរត្រូវបានអនុញ្ញាតិឲ្យសួរទៅលោក ដាវ៉ា អំពីគំនិតផ្នែកច្បាប់ទេ ។ ការជំទាស់នេះត្រូវបានទទួលយក មេធាវី ខាណាវ៉ាស បានអានសំណួរម្តងទៀតដោយសួរទៅលោក ដាវ៉ា អំពីឯកសារដែលរកឃើញដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងបណ្ណសារដ្ឋានជាតិកម្ពុជា ។ មេធាវី ខាណាវ៉ាស បានឆ្លើយតបថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានស្នើសុំសេចក្តីថ្លែងការណ៍ផ្លូវការណាមួយទាក់ទងទៅនឹងការការគ្រប់គ្រងឯកសារដែលទទួលបានពីបណ្ណសារដ្ឋានជាតិទេ តែលោក ដាវ៉ា បានបញ្ជាក់ថា លោកបានសួរពីប្រវត្តិនៃឯកសារថាតើឯកសារទាំងនោះបានមកដល់បណ្ណសារដ្ឋានដោយរបៀបណា?

ពេលសួរសំណួរបន្ថែមទៀតទាក់ទងទៅនឹងប្រធានបទនេះ លោក ដាវ៉ា បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជា មិនបានស្នើសុំឯកសារផ្លូវការណាមួយពីបណ្ណសារដ្ឋានជាតិអំពីប្រភពនៃឯកសារទេ ព្រោះបណ្ណសារដ្ឋានគឺជាស្ថាប័នដ៏ល្អមួយដែលរក្សាកំណត់ហេតុរបស់ខ្លួនបានយ៉ាងល្អ ហើយស្ថាប័ននេះនៅដំណើរការរហូតដល់សព្វថ្ងៃនេះ ។

ព័ត៌មានទាំងអស់អាចរកបាននៅបណ្ណសារដ្ឋានជាតិ លោក ដាវ៉ា ក៏បានស្នើថា ប្រើសិនបើក្រុមការពារក្តីចង់បានព័ត៌មានបន្ថែម ទាក់ទងទៅនឹងសង្វាក់នៃឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលប្រមូលមកពីបណ្ណសារដ្ឋាននេះ ខ្លួនគួរតែសួរទៅអ្នកតំណាងមកពីទីនោះផ្ទាល់ ។

ក្រោយមក មេធាវី ខាណាវ៉ាស បានសួរថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រូតូកូលផ្លូវការណាមួយ ដែលប្រើដើម្បីចងក្រងព័ត៌មានទាក់ទងទៅនឹងបណ្តាញឯកសារដែលទទួលបានពីបុគ្គលដែរឬទេ? លោក ដាវ៉ា បានឆ្លើយថា សំណួរដែលមជ្ឈមណ្ឌលឯកសារកម្ពុជាសួរទៅបុគ្គលនោះគឺអាស្រ័យលើប្រភេទឯកសារនោះផ្ទាល់ និងអាស្រ័យលើតើនរណាជាអ្នកផ្តល់ឯកសារនោះ ។ ឯកសារដែលទទួលបានពីបុគ្គលជាធម្មតាផ្តល់មកឲ្យលោកនាយក ឆាំង យុ ផ្ទាល់ ហើយក្រោយមក ឯកសារនោះត្រូវបានប្រគល់បន្តទៅលោកដើម្បីធ្វើការចុះលេខ ។ ចំពោះលោកផ្ទាល់មិនដែលទទួលបានឯកសារណាពីអ្នក

ប្រាជ្ញម្នាក់ទេ ព្រោះលោក ឆាំង យុ គឺជាអ្នកទទួលឯកសារទាំងនោះដូច្នេះលោកមិនអាចអត្ថាធិប្បាយបន្ថែមទៀតទាក់ទងទៅនឹងឯកសារនោះទេ ។

ទាក់ទងទៅនឹងឯកសារមកពីក្រសួងមហាផ្ទៃ លោក ដារ៉ា បញ្ជាក់ថា លោកកផ្ទាល់គឺជាអ្នកទៅក្រសួងមហាផ្ទៃដើម្បីទទួលឯកសារទាំងនោះ ។ មេធាវី ខាណាវ៉ាស បានសួរទៀតថា តើក្រសួងមហាផ្ទៃប្រគល់ឯកសារនោះមកមជ្ឈមណ្ឌលឯកសារកម្ពុជា ឬមជ្ឈមណ្ឌលឯកសារកម្ពុជាជាអ្នកទៅក្រសួងនោះហើយទទួលបានការអនុញ្ញាតឲ្យយកឯកសារនោះ? លោក ដារ៉ា បានឆ្លើយថា លិខិតអនុញ្ញាតិរបស់រាជរដ្ឋាភិបាល គឺអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាអាចចូលទៅស្រាវជ្រាវបានគ្រប់កន្លែងទាំងអស់ទូទាំងប្រទេស ។

នៅពេលសួរអំពីកិច្ចខិតខំប្រឹងប្រែង ដោយមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការប្រមូលឯកសារពីបរទេស លោក ដារ៉ា បានបញ្ជាក់ថា លោកនាយក ឆាំង យុ បានសរសេរលិខិតមួយ ដោយអំពាវនាវទៅគ្រប់ប្រទេសទាំងអស់ដោយស្នើឲ្យប្រគល់ឯកសារដែលទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យមកមជ្ឈមណ្ឌលឯកសារកម្ពុជា តែលោកមិនដឹងថាតើរដ្ឋាភិបាលមានបានឆ្លើយតបទៅនឹងការអំពាវនេះដែរឬអត់ទេ? តែលោកក៏បានបញ្ជាក់ដែរថា លោក ឆាំង យុ អាចឆ្លើយសំណួរនេះបានល្អជាងលោក ។

ក្រុមការពារក្តីបានបញ្ចប់ការសួរនាំ ហើយបានប្រគល់តួនាទីនេះទៅក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន ដើម្បីចោទជាសំណួរទៅលោក ដារ៉ា ។

## ក្រុមមេធាវីការពារក្តី ខៀវ សំផន ធ្វើការសាកសួរទៅលោក វ៉ាន់ថាន់ ពៅដារ៉ា

លោក គង់ សំអុន មេធាវីការពារក្តីជាតិរបស់ ខៀវ សំផន បានសួរទៅលោក ដារ៉ា ដោយចាប់សួរអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ និងប្រវត្តិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងនាមជាស្ថាប័នមួយ ។ សំណួរភាគច្រើន គឺត្រូវបានសួរដោយក្រុមមុនៗរួចហើយកាលពីពីរថ្ងៃមុន ។

អំឡុងពេលនៃការសួរសំណួរនេះ មេធាវី គង់ សំអុន បានសួរអំពីឈ្មោះគម្រោងពិតប្រាកដរបស់សាកលវិទ្យាល័យយែល ដែលជាអ្នកបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ដារ៉ា បានអះអាងថា ឈ្មោះដែលបានប្រើប្រាស់នោះគឺ «គម្រោងស្រាវជ្រាវអំពីអំពើប្រល័យពូជសាសន៍កម្ពុជា» តែលោកចាប់ផ្តើមធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ១៩៩៥ នៅការិយាល័យដែលមានទីតាំងនៅទីក្រុងភ្នំពេញ ដែលកាលនោះឈ្មោះជាផ្លូវការថា«មជ្ឈមណ្ឌលឯកសារកម្ពុជា» ។

ក្រោយមក មេធាវី គង់ សំអុន បានសួរទៅលោក ដារ៉ា ថា តើកិច្ចការរបស់មជ្ឈមណ្ឌល
ឯកសារកម្ពុជាមានដែលអះអាងខ្លួនឯងថាជា“ស្ថាប័នស៊ើបអង្កេត” ជាពិសេសទាក់ទងទៅនឹង“កម្មវិធី
ស្រាវជ្រាវពីកោសល្យវិច័យ”? លោក ដារ៉ា បានឆ្លើយថា កម្មវិធីស្រាវជ្រាវកោសល្យវិច័យត្រូវ
បានធ្វើឡើងដោយបុគ្គលផ្សេង ហើយលោកមិនអាចបកស្រាយពីកិច្ចការនេះបានទេ តែឈ្មោះរបស់
សមាជិកក្រុម ដែលពាក់ព័ន្ធកិច្ចការស្រាវជ្រាវនេះក៏អាចរកបាននៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯក
សារកម្ពុជាដែរ ។ ទាក់ទងទៅនឹងគម្រោងស្រាវជ្រាវពីរណ្ដៅសាកសពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
នោះ លោក ដារ៉ា បានបញ្ជាក់ថា គម្រោងនេះ គឺមិនមែនបង្កើតឡើងដើម្បី“ស៊ើបអង្កេត”ទេ ព្រោះ
មជ្ឈមណ្ឌលឯកសារកម្ពុជាមិនមានអំណាចផ្លូវច្បាប់ឡើយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលព័ត៌
មានទាក់ទងទៅនឹងរណ្ដៅសាកសពនៅក្នុងប្រទេសកម្ពុជាដែលជាផ្នែកមួយនៃកិច្ចការទូទៅ ។ នៅពេលសួរ
ថា តើលោកគិតយ៉ាងដូចម្ដេចអំពីកិច្ចការទូទៅរបស់គម្រោងស្រាវជ្រាវពីរណ្ដៅសាកសពនេះ លោក
ដារ៉ា បានឆ្លើយថា “ខ្ញុំគិតថាគម្រោងនេះល្អ” ដែលធ្វើឲ្យអ្នកតាមដានទស្សនាផ្ទុះសំណើចឡើង ។

ក្រោយមក មេធាវី គង់ សំអុន បានសួរអំពីសកម្មភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុង
ការបណ្ដុះបណ្ដាលនគរបាលស៊ើបអង្កេតក្នុងប្រទេសកម្ពុជា ។ លោក ដារ៉ា បានបញ្ជាក់ថា លោកមិន
ចូលរួមពាក់ព័ន្ធជាមួយសកម្មភាពបណ្ដុះបណ្ដាលនេះទេ ដូច្នេះលោកមិនអាចបកស្រាយបានទេ ។ លោក
មេធាវី គង់ សំអុន បានសួរទៅលោក ដារ៉ា ថា តើសំណួរអ្វីដែលបានសួរទៅអ្នកដែលផ្ដល់ឯកសារ
នោះមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ដារ៉ា បានបញ្ជាក់ថា ធម្មតាលោកសួរសំណួរថា តើ
ទទួលបានឯកសារនោះពីណាមក និងសំណួរផ្សេងទៀតទាក់ទងទៅនឹងបញ្ហាឯកសារនេះ ។

## អៀង សារី លះបង់សិទ្ធិនៅក្នុងបន្ទប់សវនាការនិងសុំទៅបន្ទប់រង់ចាំ

ក្រោយមក មេធាវីការពារក្ដី អៀង សារី បានក្រោកឈរមុននឹងចៅក្រមប្រកាសឲ្យឈប់
សម្រាកនៅពេលព្រឹក ហើយមេធាវីបានជម្រាបទៅអង្គជំនុំជម្រះថា អៀង សារី ចង់លះបង់សិទ្ធិនៅ
ក្នុងបន្ទប់សវនាការ ហើយទៅតាមដានដំណើរការតាមប្រព័ន្ធសោទស្សន៍វិញ ។ អង្គជំនុំជម្រះអនុញ្ញាត
តាមការទាមទារនិងបង្គាប់ឲ្យមេធាវីធ្វើលិខិតជាលាយលក្ខណ៍អក្សរ និងមានហត្ថលេខាពីជនជាប់ចោទ ។

## មេធាវីការពារក្ដី ខៀវ សំផន សួរបន្ត

ក្រោយពីសម្រាកនៅពេលព្រឹក មេធាវី គង់ សំអុន បានសួរទៅលោក ដារ៉ា អំពីសកម្មភាព
របស់លោក ក្នុងការសម្ភាសអ្នករួចរស់ជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ។ លោក ដារ៉ា បានផ្ដល់

សក្ខីកម្មថា លោកផ្ទាល់ធ្លាប់បានសម្ភាសមនុស្សជាង១០០នាក់ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ភាសមនុស្សប្រហែលជា១០០០នាក់។ មេធាវី គង់ សំអុន បានសួរអំពីតួនាទីរបស់ «ទីប្រឹក្សា» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោក ដារ៉ា បានបញ្ជាក់ថា រាល់ទីប្រឹក្សាទាំងអស់ដែលធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាគោរពតាមគោលការណ៍ ហើយបានជួយមជ្ឈមណ្ឌលឯកសារកម្ពុជាដោយមិនគិតថ្លៃ។ ទីប្រឹក្សាទាំងអស់បានជួយដល់មជ្ឈមណ្ឌលឯកសារកម្ពុជាទៅគ្រប់គម្រោងតាមជំនាញដែលខ្លួនមាន។

នៅពេលសួរអំពី«គោលបំណង»នៃការជ្រើសរើសទីប្រឹក្សានៅមជ្ឈមណ្ឌលឯកសារកម្ពុជាលោក ដារ៉ា បានឆ្លើយថា ទីប្រឹក្សាទាំងនេះជួយកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាពិសេសនៅអំឡុងពេលនៃវគ្គបណ្តុះបណ្តាលនីមួយៗ តែមជ្ឈមណ្ឌលឯកសារកម្ពុជា មិនមែន«សុទ្ធតែធ្វើតាម»អ្វីដែលទីប្រឹក្សាផ្តល់ឲ្យទេ។

មេធាវី គង់ សំអុន បានសួរថា តើទីប្រឹក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាធ្លាប់ត្រូវបានស្នើសរសេរសៀវភៅណាមួយសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ? ហើយបង្ហាញសៀវភៅនោះពីមជ្ឈមណ្ឌលឯកសារកម្ពុជាមកតុលាការនេះដែរឬទេ? សៀវភៅដែលបានបង្ហាញនេះ គឺជាគម្របសៀវភៅមួយដែលមានចំណងជើងថា ការចងក្រងបទឧក្រិដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យដែលសរសេរដោយលោក ចន ចរឌីអារី ដែលជាទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយសហការសរសេរជាមួយនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឆាំង យុ។

មេធាវី គង់ សំអុន បានសួរថា តើលោក ចន ចរឌីអារី មានដែលវិភាគឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ? លោក ដារ៉ា បានឆ្លើយដោយសាមញ្ញថា ទីប្រឹក្សាជំនាញដូចជាលោក ចន ចរឌីអារី បានផ្តល់ប្រឹក្សាមកមជ្ឈមណ្ឌលឯកសារកម្ពុជាអំពីកិច្ចការជាច្រើន តែទីប្រឹក្សាមិនទទួលយកយោបល់របស់លោកទាំងស្រុងទេ។

ក្រោយមក មេធាវី គង់ សំអុន បានស្នើទៅលោក ដារ៉ា ឲ្យអានផ្នែកមួយនៃអត្ថបទជាភាសាអង់គ្លេស។ លោក ដារ៉ា បានបដិសេធដោយបញ្ជាក់ថា លោកចង់អានជាភាសាខ្មែរតែប៉ុណ្ណោះ។ ពេលនេះអង្គជំនុំជម្រះបានចូលមកអន្តរាគមន៍ ហើយណែនាំទៅមេធាវី គង់ សំអុន និងភាគីដទៃទៀតថា មិនត្រូវស្នើលោក ដារ៉ា អានភាសាអង់គ្លេស ព្រោះលោកមានសិទ្ធប្រើប្រាស់ភាសាខ្មែរ។

មេធាវី គង់ សំអុន បានអានផ្នែកនោះដោយប្រើពាក្យថា «ឯកសារជាភ័ស្តុតាង» ដើម្បីពណ៌នាឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយក្រោយមកមេធាវីបានប្រគល់តួនាទីនេះទៅសហមេធាវីអន្តរជាតិ ហ្សាក់ វើគហ្សេស ដើម្បីសួរសំណួរបន្ត។

មេធាវី ហ្សាក់ វើគហ្សេស បានចាប់ផ្ដើមសួរអំពីហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ មេធាវីរូបនេះបានសួរទៅលោក ដារ៉ា ថា តើលោកប្រាកដបែបណាដែលថាអ្នកផ្ដល់ឯកសារមកមជ្ឈមណ្ឌលឯកសារកម្ពុជា«មិនមានលក្ខខណ្ឌ»អ្វីនោះ បើលោកមិនទាំងប្រាកដខ្លួនឯងអំពីបញ្ហាហិរញ្ញវត្ថុផងនោះ? លោក ដារ៉ា បានឆ្លើយថា លោកដឹងពីអត្តសញ្ញាណម្ចាស់ជំនួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា តែលោកមិនដឹងអំពីចំនួនពិតប្រាកដដែលម្ចាស់ជំនួយនីមួយៗផ្ដល់ឲ្យទេ លោកក៏មិនអាចចាំម្ចាស់ជំនួយអស់ដែរ ។

មេធាវី ហ្សាក់ វើគហ្សេស បានសួរថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាអាចបន្តកិច្ចការជាមួយម្ចាស់ជំនួយមួយដែលជឿថា «បទឧក្រិដ្ឋទាំងអស់ត្រូវបានប្រព្រឹត្តិឡើងដោយសហរដ្ឋអាមេរិក» នោះ ។ លោក ដារ៉ា បានឆ្លើយថា រាល់ម្ចាស់ជំនួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់តម្រូវឲ្យមានតម្លាភាពនិងប្រសិទ្ធភាព ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានត្រួតពិនិត្យហិរញ្ញវត្ថុយ៉ាងម៉ត់ចត់ ។ មេធាវីរូបនេះបានអះអាងទៀតថា នេះ«គឺជាការសម្ងាត់មួយ ហើយក៏ជាបញ្ហាដែរ» ហើយបញ្ជាក់ថាប្រហែលជាលោក ដារ៉ា ត្រូវការ«ព្យាបាលជំងឺសតិវិបល្លាស»ហើយ ។

ក្រោយមក ព្រះរាជអាជ្ញាជំទាស់ទាក់ទងទៅនឹងទម្រង់នៃការសួរដោយមេធាវី ហ្សាក់ វើគហ្សេស ដោយបញ្ជាក់ថា គេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរាយនាមម្ចាស់ជំនួយទាំងអស់ ហើយថា បញ្ជីនោះវែងបន្តិច ហើយ«មិនមានបញ្ហាអ្វីទេ» ។

ទោះបីជាព្រះរាជអាជ្ញាជំទាស់បែបនេះក៏ដោយ មេធាវី ហ្សាក់ វើគហ្សេស បានបន្តសួរទៅទៀត តែត្រូវអង្គជំនុំជម្រះជំទាស់ និងរិះគន់មេធាវីរូបនេះដែលប្រាប់លោក ដារ៉ា ឲ្យព្យាបាលសតិអារម្មណ៍របស់គាត់នោះ ។ ចៅក្រម និល ណុន បានបញ្ជាក់ថា លោក ដារ៉ា កំពុងតែចាំស្ដាប់សំណួរដែលកំពុងតែបកប្រែ ហើយចៅក្រមបានរំឭកទៅមេធាវីរូបនេះឲ្យប្រើភាសាសមរម្យនៅក្នុងបន្ទប់សវនាការ ។

មេធាវី ហ្សាក់ វើគហ្សេស បានសួរទៅលោក ដារ៉ា ថា យ៉ាងហោចណាស់ក៏លោកចាំឈ្មោះស្ដាប័នមួយចំនួនដែលបានផ្ដល់មូលនិធិមកមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ។ លោក ដារ៉ា បានបញ្ជាក់ថា លោកចាំឈ្មោះស្ដាប័នមួយចំនួនដូចជា USAID (សហរដ្ឋអាមេរិក) និង Sida (ស៊ុយអ៊ែត) ។ មេធាវី ហ្សាក់ វើគហ្សេស បានសួរឈ្មោះសាកលវិទ្យាល័យមួយចំនួនដែលកំពុងធ្វើការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ដារ៉ា បានឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការជាមួយសាកលវិទ្យាល័យយែល សាកលវិទ្យាល័យញូសៅវែល សាកលវិទ្យាល័យសាន់តាក្លារ៉ា និងសាកលវិទ្យាល័យរ៉ាត់ហ្គើស ជាដើម

ក្រោយមក មេធាវី ហ្សាក់ វើគហ្វេស បានសួរថា តើនរណាជាអ្នកបង្កើតបញ្ជីសំណួរសម្រាប់សម្ភាស ។ លោក ដារ៉ា បានឆ្លើយថា លោក ចន ចរឆីអារី ជាអ្នកព្រាងឯកសារនោះដំបូង តែក្រោយមកត្រូវបានបកប្រែជាភាសាខ្មែរ ហើយបុគ្គលិកបានយកបញ្ជីសំណួរនេះពេលចុះទៅសម្ភាសប្រជាជន ។

ក្រោយមក មេធាវីរូបនេះបានសួរអំពីថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាចាត់ទុកឯកសារដែលទទួលបានពីវៀតណាម "អាចទុកចិត្ត" បានដែរឬទេ ព្រោះវៀតណាមមិនមានជំនាញចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជាទេ ។ ព្រះរាជអាជ្ញាបានជំទាស់ម្តងទៀតដោយបញ្ជាក់ថា បញ្ហានេះត្រូវបានហាមឃាត់ដោយព្រះរាជអាជ្ញាម្តងហើយ ហើយលោក ដារ៉ា មិនត្រូវបានឲ្យឆ្លើយនិងសំណួរដែលបញ្ចេញគំនិតយោបល់ផ្ទាល់ខ្លួនទាក់ទងទៅនឹងឯកសារដែលទទួលបានពីប្រទេសវៀតណាមទេ ។ អង្គជំនុំជម្រះយល់ស្របទៅនឹងការជំទាស់នេះ ហើយណែនាំទៅមេធាវី ហ្សាក់ វើគហ្វេស ឲ្យដូរសំណួរ ។

មេធាវី ហ្សាក់ វើគហ្វេស បានសួរបន្តទៀតអំពីប្រភេទនៃក្រដាសដែលបានប្រើក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មេធាវីបានសួរថាតើក្រដាសដែលបានប្រើនៅក្នុងប្រទេសកម្ពុជានិងវៀតណាមមានការផ្លាស់ប្តូរដែរឬទេក្នុងរយៈពេល២៥ឆ្នាំនេះ? លោក ដារ៉ា បានឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជា បានត្រួតពិនិត្យក្រដាសដែលបានប្រើប្រាស់កាលពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយថា ក្រដាសនោះមានភាពងាយស្រួលក្នុងការស្គាល់ណាស់ដោយត្រឹមតែភ្នែកទទេប៉ុណ្ណោះ យើងអាចដឹងថា ឯកសារនោះចាស់ឬថ្មី ។

មេធាវី ហ្សាក់ វើគហ្វេស បានបញ្ជាក់ថា លោកទទួលយកនូវចម្លើយនេះ ទោះបីជាច្បាស់ហើយថា លោកមិនពេញចិត្តទៅនឹងចម្លើយនេះក៏ដោយ ។ ពេលនេះ ចៅក្រម បានថ្លែងអំណរគុណដល់លោក វ៉ាន់ថាន់ ពៅដារ៉ា ដែលបានផ្តល់សក្ខីកម្មអស់រយៈពេលពីរថ្ងៃកន្លះមកនេះ ។

## នួន ជា ហត់នឿយ និងស្នើទៅកាន់បន្ទប់រង់ចាំ

មេធាវីរបស់ នួន ជា បានស្នើឲ្យកូនក្តីរបស់គាត់ទៅសម្រាកដូចសព្វដង និងសុំទៅតាមដានដំណើរការតុលាការក្នុងបន្ទប់សោទស្សន៍វិញ ។ អង្គជំនុំជម្រះបានផ្តល់ការអនុញ្ញាតនេះដូចសព្វមួយដងដែរ ហើយប្រាប់ទៅមេធាវីឲ្យប្រគល់ឯកសារជាលាយលក្ខណ៍អក្សរមកអង្គជំនុំជម្រះអំពីមូលហេតុនៃអវត្តមាននេះ ជាជាងគ្រាន់តែសុំត្រឹមមាត់ទទេ ។

## អង្គជំនុំជម្រះប្រកាសថា កាលវិភាគនៅរសៀលនេះនឹងមានរយៈពេលខ្លី

នៅពេលដែលអង្គជំនុំជម្រះចាប់ផ្ដើមក្រោយពីអាហារថ្ងៃត្រង់ ចៅក្រម និល ណុន បានជម្រាបទៅគ្រប់ភាគីថា អង្គជំនុំជម្រះនឹងបញ្ចប់នៅម៉ោង២:៤០នាទីរសៀលនេះ ដោយសារតែចៅក្រមរបស់អង្គជំនុំជម្រះត្រូវជួបប្រជុំគ្នានៅពេលនេះ និងពិភាក្សាអំពី«បញ្ហាផ្សេងៗ» ។

## អង្គជំនុំជម្រះបានត្រលប់ទៅធ្វើសក្ខីកម្មជាមួយនិងសាក្សី ប្រាក់ យុត

ការធ្វើសក្ខីកម្មរបស់លោក វ៉ាន់ថាន់ ពៅដារ៉ា បានបញ្ចប់លើបញ្ហាភស្តុតាងនៅក្នុងករណី ០០២ ។ ក្រោយមកអង្គជំនុំជម្រះបានអញ្ជើញសាក្សីបន្ទាប់ដែលគ្រោងនឹងចូលមកធ្វើសក្ខីកម្មទាក់ទងទៅនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីរូបនេះមានឈ្មោះ ប្រាក់ យុត ដែលមានដើមកំណើតនៅស្រុកត្រាំកក់ ខេត្តតាកែវ ហើយសព្វថ្ងៃរស់នៅក្នុងខេត្តបាត់ដំបង ។ ក្រោយពីការសួរសំណួរបឋមមួយចំនួនដោយប្រធានអង្គជំនុំជម្រះ ចៅក្រមបានប្រគល់តួនាទីនេះទៅភាគីព្រះរាជអាជ្ញាដើម្បីធ្វើការចោទសួរ ។

## ព្រះរាជអាជ្ញាសួរទៅ ប្រាក់ យុត

សេង ប៊ុនយៀង ព្រះរាជអាជ្ញាជាតិ ចាប់ផ្ដើមសួរទៅ ប្រាក់ យុត អំពីបទពិសោធន៍របស់គាត់ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រាក់ យុត ឆ្លើយថា គាត់បានចូលក្នុងចលនាបដិវត្តន៍ខ្មែរក្រហម ព្រោះកាលពីជំនាន់នោះនរណាក៏ចូលដែរ ។ កាលនោះ ប្រាក់ យុត នៅក្មេងហើយក៏មិនដែលបានចូលរៀននៅសាលាដែរ គាត់ក៏មិនដឹងពីគោលនយោបាយរបស់ខ្មែរក្រហមអ្វីដែរ ។ កាលពីដំបូងគាត់ត្រូវបានចាត់តាំងឲ្យចូលនៅក្នុងក្រុមឃ្វាលគោ ក្រោយមកគាត់ត្រូវបានតម្លើងតួនាទីទៅជាប្រធានកងចល័ត ។ កាលនោះមានមនុស្សប្រមាណពី ២០០ទៅ៣០០នាក់ នៅក្នុងកងចល័តរបស់គាត់ដែលមានតួនាទីលើកទំនប់និងធ្វើកិច្ចការដទៃទៀត ។ សមាជិកនៅក្នុងកងចល័តរបស់គាត់ត្រូវបាន«ប្រមូល»មកពីតាមភូមិនានា តែគាត់មិនដឹងថា សមាជិកទាំងនោះត្រូវបានជ្រើសរើសឲ្យចូលក្នុងកងចល័តរបស់គាត់ដោយរបៀបណាទេ ។ សាក្សី ប្រាក់ យុត បានបញ្ជាក់ថា សមាជិកកងចល័តទាំងអស់មានអាយុប្រមាណជា១៥ឆ្នាំ ។

ក្រោយមក សេង ប៊ុនយៀង បានសួរអំពីទំនប់ដែលក្រុមរបស់ ប្រាក់ យុត បានជីក ។ ប្រាក់ យុត បានឆ្លើយថា គាត់មិនចាំអំពីការលើកទំនប់នោះទេ ។ ពេលសួរអំពីលក្ខខណ្ឌរស់នៅឯការដ្ឋាននោះ គាត់បានបញ្ជាក់ថា របបអាហារ«មានគ្រប់គ្រាន់»សម្រាប់មនុស្សនៅកន្លែងរបស់គាត់ ។

ត្រង់ចំណុចនេះ លោក ម៉ៃឃើល ផេស្តមែន មេធាវីការពារក្តីអន្តរជាតិរបស់ នួន ជា បាន ងើបឡើង ហើយស្នើសុំឲ្យមានការបញ្ជាក់ឲ្យច្បាស់ទាក់ទងទៅនឹងពេលវេលា និងហេតុការណ៍ដែលបាន សួរទៅសាក្សី ។ មេធាវីការពារក្តីបានបញ្ជាក់ថា មិនច្បាស់ទេត្រង់ថា សក្ខីកម្មរបស់គាត់ គឺទាក់ទងទៅនឹងដំណាក់កាលទីមួយនៃករណី០០២ឬអត់«សវនាការដំបូង» ។

នៅពេលសួរអំពីពេលវេលា ប្រាក់ យុត បានអះអាងថា គាត់នឹកមិនឃើញពីហេតុការណ៍ និងពេលវេលាជាក់លាក់ទេ តែអ្វីដែលគាត់និយាយភាគច្រើននៅរយៈពេលដើមទសវត្សរ៍៧០ ។ ក្រោយមក សេង ប៊ុនឃៀង បន្តសួរទៅសាក្សីអំពីទិដ្ឋភាពពិតប្រាកដនូវអ្វីដែលសាក្សីបាននិយាយ កាលពីមុនមកកាន់អង្គជំនុំជម្រះនេះ ។

ចំណុចនេះត្រូវបានជំទាស់ដោយមេធាវី ផេស្តមែន ដែលអះអាងថា បើសិនជាសួរទាក់ទងទៅនឹងរយៈកាលក្រោយឆ្នាំ១៩៧៥ សក្ខីកម្មនេះ គឺមិនពាក់ព័ន្ធទៅនឹងប្រធានបទអំពីប្រវត្តិនៃការកកើតកម្ពុជាប្រជាធិបតេយ្យទេ ។

ភ្លាមនោះ ម៉ៃឃើល ខារណាវ៉ាស មេធាវីការពារក្តីរបស់ អៀង សារី ក៏ជំទាស់ដែរ ដោយអះអាងថា ព្រះរាជអាជ្ញាមិនបានប្រើប្រាស់ពេលវេលាឲ្យបានសមរម្យទេ ហើយសួរឡើងវិញនូវអ្វីដែលសាក្សីធ្លាប់និយាយរួចហើយ ដាដាងសួរដើម្បីឲ្យគាត់រំឭកពីអ្វីដែលគាត់ធ្លាប់និយាយនោះ ។ អង្គជំនុំជម្រះបានយល់ស្របទៅជំទាស់ទាំងពីរនេះ ហើយណែនាំទៅព្រះរាជអាជ្ញាឲ្យផ្តោតទៅនឹងប្រធានបទដែលបានគ្រោងទុក ។ ក្រោយមក ព្រះរាជអាជ្ញាបានសួរសំណួរផ្សេងទៀតទាក់ទងទៅនឹងប្រធានបទអំពីជំរុំកែប្រែ ដែលសាក្សីរូបនេះធ្លាប់រស់នៅ ។ សាក្សីរូបនេះបានរៀបរាប់អំពីជំរុំកែប្រែមួយចំនួន ហើយអះអាងថា គាត់ដឹងរឿងនេះមិនសូវច្រើនទេ ព្រោះការគ្រប់គ្រងជំរុំនោះគឺជាភារកិច្ចរបស់អ្នកផ្សេងទៀត ។

ទាក់ទងទៅនឹងមនោគមន៍វិជ្ជា និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រាក់ យុត បានបកស្រាយថា គាត់មិនយល់អំពីប្រធានបទនេះទេ ព្រោះគាត់មិនចេះអក្សរ ។ គាត់ធ្លាប់បានចូលរួមក្នុងវគ្គសិក្សាខ្លះ តែ«មិនបានយល់ជ្រៅជ្រះទេ»នៅពេលនោះ ។

ក្រោយមក ព្រះរាជអាជ្ញាសួរអំពីរបៀបក្នុងការទទួលរបាយការណ៍ពីមនុស្សនៅក្រោមបង្គាប់ និងរបៀបក្នុងការបញ្ជូនរបាយការណ៍ទៅថ្នាក់លើក្នុងនាមជាសមាជិកម្នាក់របស់តំបន់៣៥ ។ ប្រាក់ យុត និយាយថា «នរណាក៏ត្រូវរាយការណ៍ពីកិច្ចការណ៍របស់ខ្លួនដែរ» តែគាត់មិនដឹងអំពីរបាយការណ៍អ្នកផ្សេងទៀតទេ ព្រោះមាន«តួនាទីផ្សេងគ្នា» ។ ពេលសួរសំណួរបន្ថែមទៀត ប្រាក់ យុត បានបញ្ជាក់ឲ្យច្បាស់ថា ថ្នាក់ដឹកនាំស្រុករាយការណ៍ទៅថ្នាក់តំបន់ ។

នៅពេលសួរអំពីការថាតើ«អំពើខុសសីលធម៌» មានដែលយកមកនិយាយអំឡុងពេលកិច្ចប្រជុំនីមួយៗទេ ប្រាក់ យុត បានឲ្យដឹងថា ប្រធានបទនេះត្រូវបានយកមកពិភាក្សា និងពាក្យថា «អំពើខុសសីលធម៌» នេះគឺពាក់ព័ន្ធទៅនឹង«ការបែចង់ស្រី» ។ ក្រោយមក សាក្សីរូបនេះបានបញ្ជាក់ថា នៅថ្នាក់ស្រុក បុគ្គលណាដែលជាប់ពាក់ព័ន្ធទៅនឹងការខុសសីលធម៌នឹងត្រូវ«យកទៅអប់រំ» ។ ការប្រជុំភាគច្រើននិយាយតែពីការលើកទំនប់ប្រឡាយ និងបញ្ហាស្រដៀងគ្នានេះ ។ គាត់មិនដឹងថាតើរបាយការណ៍ត្រូវបានបញ្ជូនទៅថ្នាក់លើដោយវិធីណាទេ ។ ទាក់ទងទៅនឹងកិច្ចប្រជុំថ្នាក់តំបន់ ប្រាក់ យុត បានបញ្ជាក់ថា លេខាតំបន់ទទួលការណែនាំពីថ្នាក់ភូមិភាគ ហើយថ្នាក់តំបន់បានរៀបចំកិច្ចប្រជុំនៅថ្នាក់ស្រុក ដើម្បីផ្សព្វផ្សាយព័ត៌មានទាំងអស់នោះទៅថ្នាក់ក្រោម ។

ក្រោយមក សាក្សីត្រូវបានសួរអំពីតួនាទីរបស់ខ្លួននាដើមទសវត្សរ៍៧០ទាក់ទងទៅនឹងកិច្ចការនារី ។ ប្រាក់ យុត បានផ្តល់សក្ខីកម្មថា គាត់បានកាន់តំណែងនេះរហូតដល់ឆ្នាំប្រហែលជា១៩៧៣ក្នុងខេត្តកំពត ហើយនៅក្នុងតួនាទីនេះ គាត់បានបង្រៀននារីផ្សេងទៀតអំពីភារកិច្ចដើម្បីបំពេញចំពោះការងារ ។ ប្រាក់ យុត បាននិយាយទៀតថា ក្រោយមកគាត់ត្រូវបានបញ្ជូនទៅខេត្តកំពង់ចាមប្រហែលជាឆ្នាំ១៩៧៣ ហើយគាត់មិនដឹងថាហេតុអ្វីបានជាគាត់ត្រូវបញ្ជូនឲ្យទៅទីនោះទេ ។

ពេលនៅខេត្តកំពង់ចាម ប្រាក់ យុត បានបញ្ជាក់ថា ជួនកាលគាត់ដឹកនាំវគ្គបណ្តុះបណ្តាលដើម្បីបង្រៀនមនុស្សអំពីវិធីសាស្ត្រលើកទំនប់ប្រឡាយ និងធ្វើកិច្ចការផ្សេងទៀត ដូចជាធ្វើទ្វារទឹកជាដើម ។ គាត់បានក្លាយជាលេខាស្រុកក្នុងខេត្តកំពង់ចាម ហើយលេខាតំបន់ជាអ្នកប្រាប់គាត់ឲ្យតែងតាំងលេខាឃុំ ។

ក្រោយមក ព្រះរាជអាជ្ញាបានសួរអំពីទីតាំងគុកពីរកន្លែងនៅតំបន់ដែល ប្រាក់ យុត ធ្លាប់កាន់កាប់តែគាត់បានឆ្លើយថា គាត់មិនដឹងអំពីកិច្ចការនៅទីតាំងទាំងពីរនេះទេ ព្រោះម្នាក់ៗផ្តោតទៅលើតែការងាររៀងៗខ្លួនប៉ុណ្ណោះ ។

ក្រោយមក ប្រាក់ យុត ត្រូវបានសួរអំពីកិច្ចការលើកទំនប់នៅខេត្តកំពត ។ សាក្សីរូបនេះបានបកស្រាយថា ភាគច្រើនគាត់ធ្វើស្រែកាលពីជំនាន់នោះ ហើយដឹងតិចតួចណាស់ទាក់ទងទៅនិងលក្ខខណ្ឌការងារនៅទីតាំងលើកទំនប់នោះ ។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះបានបញ្ចប់កិច្ចការនេះ ។ ប្រធានអង្គជំនុំជម្រះ និល ណុន បានជម្រាបទៅគ្រប់ភាគីថា កិច្ចដំណើរការនឹងបន្តនៅថ្ងៃស្អែកនៅវេលាម៉ោង៩:០០ព្រឹក ដោយបន្តការធ្វើសក្ខីកម្មរបស់ ប្រាក់ យុត ។

– ចប់ –